*សេចក្តីប្រកាសព័ត៌មានរួម*

# កម្ពុជាបង្ហាញការប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការការពារសត្វផ្សោតទន្លេមេគង្គ លើឆាកអន្តរជាតិតាមរយៈសិល្បៈ និងវិទ្យាសាស្ត្រ

វីដេអូបទចម្រៀង «ផ្សោតដួងចិត្ត» ដែលច្រៀងដោយអ្នកនាង មាស សុខសោភា បង្ហាញអំពីមោទកភាពនៃវត្តមានសត្វផ្សោតទន្លេមេគង្គកម្ពុជា នៅក្នុងកិច្ចប្រជុំអន្តរជាតិស្តីពី "ការថ្លែងជាសកលក្នុងការការពារសត្វផ្សោតទឹកសាបពិភពលោក" នៅប្រទេសកូឡុំប៊ី កាលពីថ្ងៃចន្ទ ទី២៣ ខែតុលា ឆ្នាំ២០២៣ (ត្រូវនឹងថ្ងៃអង្គារ ទី២៤ ខែតុលានៅកម្ពុជា)។ ភ្ជាប់ជាមួយគ្នានេះ គណៈប្រតិភូតំណាងកម្ពុជាមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលជលផល និងតំណាងពីអង្គការ WWF កម្ពុជា ក៏បានបង្ហាញពីការសមិទ្ធិផលការងារ ការស្រាវជ្រាវតាមបែបផែនបច្ចេកទេសវិទ្យាសាស្ត្រ និងការប្តេជ្ញាចិត្តក្នុងការអភិរក្សសត្វផ្សោតទឹកសាបក្នុងប្រទេសផង។

**លោកជំទាវ អ៊ឹម រចនា អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** បានមានប្រសាសន៍ថា៖ "នៅក្នុងការចូលរួមប្រជុំនៅប្រទេសកូឡុំប៊ីនាឱកាសនេះ កម្ពុជាបានបង្ហាញពីសក្តានុពលនៃធនធានជលផល និង ការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់ខ្លួនក្នុងការការពារសត្វផ្សោតទន្លេមេគង្គដ៏មានតម្លៃឥតគណនា។ រាជរដ្ឋាភិបាលកម្ពុជា ផ្តោតការយកចិត្តទុកដាក់ដល់កិច្ចការពារអភិរក្សសត្វផ្សោត និងធនធានវារីសាស្ត្រក្នុងតំបន់ ស្របតាមគោលនយោបាយបញ្ចកោណ ដោយគាំទ្រ និងជម្រុញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធរាប់ចាប់ពីអ្នកសិល្បៈ សហគមន៍មូលដ្ឋាន អ្នកបច្ចេកទេសវិទ្យាសាស្ត្រ ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិនានា រួមគ្នាដើម្បីធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ធន់នឹងការប្រែប្រួលអាកាសធាតុ។"

**អ្នកនាង មាស សុខសោភា តារាចម្រៀង** ដែលមានអ្នកគាំទ្រជាង៥លាននាក់ក្នុងបណ្តាញហ្វេសប៊ុក បានលើកឡើងថា៖ "ខ្ញុំមានមោទកភាពណាស់ដែលបានច្រៀង និងបង្ហាញពីសម្បត្តិធម្មជាតិរបស់កម្ពុជាទៅអន្តរជាតិ ជាពិសេសសអំពីសត្វផ្សោតទន្លេមេគង្គដែលត្រូវបានចាត់ទុកថាជារតនសម្បត្តិជាតិមានជីវិត។ នេះគឺជាមោទកភាពមួយយ៉ាងធំធេង ដែលយើងទាំងអស់គ្នាត្រូវចូលរួមថែរក្សាការពារ និងគាំទ្រការអភិរក្សសត្វផ្សោតទន្លេមេគង្គទាំងអស់គ្នា ដើម្បីរក្សាបរិស្ថានធម្មជាតិ និងទាក់ទាញភ្ញៀវទេសចរមកកម្ពុជាកាន់តែច្រើនឡើង។"

កម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន១៤ប៉ុណ្ណោះក្នុងពិភពលោក ដែលនៅមានវត្តមានសត្វផ្សោតទឹកសាបដ៏កំររស់នៅក្នុងទន្លេ (មេគង្គ)។ សត្វផ្សោតទឹកសាបសរុប៦ប្រភេទកំពុងប្រឈមនឹងការផុតពូជ ដូច្នេះហើយទើបប្រទេសនានាដែលនៅសេសសល់វត្តមានសត្វផ្សោតទឹកសាប ចូលរួមបង្ហាញការប្តេជ្ញាចិត្តរួមគ្នាដើម្បីការពារសត្វផ្សោត និងទីជម្រករបស់ពួកវាក្នុងការប្រជុំនៅប្រទេសកូឡុំប៊ី នាថ្ងៃទី២៣ និង២៤ ខែតុលា ឆ្នាំ២០២៣នេះ។

**លោកសេង ទៀក នាយកអង្គការWWF** បានមានប្រសាសន៍ថា៖ "ការចូលរួមពីគ្រប់ភាគីទាំងអស់គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការការពារ និងអភិរក្សសត្វផ្សោតទន្លេមេគង្គ។ តួយ៉ាងនៅក្នុងការប្រជុំអន្តរជាតិនេះ មានការប្តេជ្ញារួមគ្នាការពារសត្វផ្សោតទឹកសាបក្នុងពិភពលោក។ កម្ពុជាបានកៀរគរការចូលរួមពីអ្នកមានប្រជាប្រិយភាពក្នុងសង្គមដូចជាអ្នកនាងសោភា អ្នកបច្ចេកទេសវិទ្យាសាស្ត្រពីរាជរដ្ឋាភិបាលដោយធ្វើការក្នុងភាពជាដៃគូយ៉ាងល្អជាមួយអង្គការWWF បង្ហាញពីសុឆន្ទៈរួមដ៏សំខាន់ដើម្បីផ្តល់ក្តីសង្ឃឹមដល់ការរស់រាននៃសត្វផ្សោតទន្លេមេគង្គ។"

***

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***

កញ្ញា រ៉ាវី សុភារ័ត្ន  មន្រ្តីជាន់ខ្ពស់ផ្នែកកិច្ចការសាធារណៈនៃអង្គការWWF

លេខទូរស័ព្ទ៖ ០៧០៤០៩២៧៦

***ឯកសារសំខាន់ៗ***

- តំណភ្ជាប់ទៅ បទចម្រៀង៖ https://youtu.be/TcPu90VwjJg
- តំណភ្ជាប់ទៅរូបភាព និងវីដេអូ (ត្រូវស្នើរ / request access needed)៖ https://drive.google.com/drive/folders/1MpHRCNVFGKBV2DGOgL6sJ3dO_h-g6_Pv?usp=share_link

## *Note to Editor :*

ក្រៅពីវីដេអូចម្រៀងអំពីសត្វផ្សោតដើម្បីផ្សព្វផ្សាយ និងផ្ដល់ចំណេះដឹងអំពីសារៈសំខាន់នៃការអភិរក្សសត្វផ្សោតនិងប្រភេទសត្វព្រៃវិសាស្ត្រផ្សេងទៀតនៅទន្លេមេគង្គដល់សាធារណៈជន  អង្គការ WWF សហការជាមួយវិទ្យាស្ថានភាសាបារាំង និងមានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ និងរដ្ឋបាលជលផល បានដាក់ដំណើរ «ពិព័រណ៍រូបថតសត្វផ្សោតទន្លេមេគង្គ» រយៈពេលមួយខែពេញ(ចាប់ពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ តទៅ) នៅវិទ្យាស្ថានភាសាបារាំង។ ការចូលរួមទស្សនាគឺឥតបង់ថ្លៃឡើយ។

សត្វផ្សោតទន្លេមេគង្គ ឬផ្សោតក្បាលត្រឡោក *(Orcaella brevirostris)* ជាសត្វផ្សោត ១ ប្រភេទ ក្នុងចំណោមសត្វផ្សោតទឹកសាបតែ៦ប្រភេទគត់ដែលមានរស់នៅក្នុងភពផែនដីយើងនេះ។ សត្វផ្សោតប្រភេទនេះ ត្រូវបានចាត់ថ្នាក់ក្នុងបញ្ជីក្រហមជា «ប្រភេទសត្វសត្វជិតផុតពូជ» ដោយអង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ(IUCN)។ បច្ចុប្បន្ន សត្វផ្សោតទន្លេមេគង្គ មានវត្តមាននៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ក្នុងប្រព័ន្ធទន្លេចំនួន៣ ប៉ុណ្ណោះ រួមមាន ទន្លេមេគង្គ (កម្ពុជា) ទន្លេអាយ៉េយ៉ាវ៉ាឌី (ប្រទេសមីយ៉ាន់មា) និងទន្លេមហាកាម (ឥណ្ឌូនេស៊ី)។

ផ្សោតទន្លេមេគង្គ ជានិមិត្តរូបដ៏អស្ចារ្យមួយរបស់ទន្លេមេគង្គ។ កាលពីអតីតកាល គេប្រទះឃើញមានវត្តមានពួកវារស់នៅតាមដងទន្លេចាប់ ពីព្រំដែនកម្ពុជា-ឡាវ ចុះតាមទន្លេមេគង្គរហូតដល់តំបន់ដីសណ្តក្នុងប្រទេសវៀតណាម និងទន្លេសាបផងដែរ។ ផ្អែកតាមទិន្នន័យឆ្នាំ២០២០  អ្នកវិទ្យាសាស្ត្របានប៉ាន់ប្រមាណថា សត្វផ្សោតទន្លេមេគង្គដែលជំពេញវ័យមានចំនួនប្រមាណ ៨៩ក្បាលតែប៉ុណ្ណោះ ដែលកំពុងរស់នៅ តាមដងទន្លេមេគង្គនៃប្រទេសកម្ពុជា។ នៅរដូវប្រាំងចាប់ពីខែមករា ដល់ខែឧសភា ក្នុងកំឡុងពេលទឹកស្រក សត្វផ្សោតប្រមូលផ្តុំគ្នា នៅក្នុង អន្លង់ទឹកជ្រៅចំនួន៨កន្លែងតាមដងទន្លេមេគង្គដែលមានចម្ងាយប្រមាណ១៨០គីឡូម៉ែត្រ លាតសន្ធឹងពីខេត្តក្រចេះ ទៅដល់ខេត្ត ស្ទឹងត្រែង។

ការការពារសត្វផ្សោតទន្លេមេគង្គ គឺជាសកម្មភាពដ៏ឧត្តមដែលនាំមកនូវអត្ថប្រយោជន៍ជាច្រើន រាប់បញ្ចូលទាំងផលប្រយោជន៍ខាងការអភិវឌ្ឍសេដ្ឋកិច្ច ការគ្រប់គ្រង និងការស្តារប្រព័ន្ធជីវចម្រុះ ដែលអាចជួយបង្កើតភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ យើងគ្រប់ៗគ្នា ចាំបាច់សហការគ្នាដើម្បីចាត់វិធានការបន្ថែម បញ្ឈប់ការដាក់មងក្នុងអន្លង់ផ្សោត និងការនេសាទដោយប្រើប្រាស់ឧបករណ៍ខុសច្បាប់។ វិធានការអភិរក្សដ៏តឹងរឹងនិងម៉ឺងម៉ាត់មួយ គឺចាំបាច់ត្រូវប្រកាន់យកដើម្បីគ្រប់គ្រងសត្វផ្សោតទន្លេនិងការពារទីជម្រករបស់ពួកវាឱ្យ បាន គង់វង្សសម្រាប់កូនចៅជំនាន់ក្រោយ។ ទីជម្រកសត្វផ្សោត ក៏ជាទីជម្រកត្រីមេពូជនិងធនធានវារីសត្វជាច្រើនប្រភេទផ្សេងទៀតផងដែរ។
សូមចុចតំណនេះដើម្បីចុះឈ្មោះផ្តល់សំឡេង និងគាំទ្រដល់ការអភិរក្សសត្វផ្សោតទន្លេមេគង្គ https://bit.ly/46AGYq1